## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៥ .—** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច_ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន និងអភិបាលខេត្ត_ក្រុងទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

## អនុក្រឹត្យ លេខ : ១១ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់សំណង់វារីអគ្គិសនីស្ទឹងមេទឹក (មណោម) នៃព្រះរាជាណាចក្រកម្ពុជា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- យោងតាមព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– តាមសំណើរបស់អង្គប្រជុំអន្តរក្រសួងស្តីពីគំរោងស្ថាបនាវារីអគ្គិសនីលើស្ទឹងមេទឹក (មណាម) នាថ្ងៃ ទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**សំរេច**

**មាត្រា ១** : បង្កើតគណៈកម្មការអន្តរក្រសួងមួយមានឈ្មោះថា :«គណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក(មណាម) នៃព្រះរាជាណាចក្រកម្ពុជា «ហៅកាត់ថា «គ.វ.ក» ។

**មាត្រា ២** : គណៈគណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក (មណាម) មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១–ឯកឧត្តម **អ៊ុង គៀត** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សហប្រធាន |
| ២–ឯកឧត្តម **ឡោ បាញ់** | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | សហប្រធាន |
| ៣–ឯកឧត្តម **សុខ អាន** | សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤–ឯកឧត្តម **ទ៉េង សិរីវុឌ្ឍ** | សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥–ឯកឧត្តម **ម៉ុក ម៉ារ៉េត** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៦–ឯកឧត្តម **ពូ សុធីរៈ** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | សមាជិក |
| ៧–ឯកឧត្តម **តាវ សេងហួរ** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៨–ឯកឧត្តម **អ៊ុច គឹមអន** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩–ឯកឧត្តម **អ៊ុម ឈុនលីម** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១០–ឯកឧត្តម **ស៊ុន ចាន់ថុល** | អគ្គលេខាធិការក្រុមប្រឹក្សា | |

អភិវឌ្ឍន៍កម្ពុជា សមាជិក

១១-ឯកឧត្តម **ឆាយ ថន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

**មាត្រា ៣** : គណៈកម្មការរ៉ាវីអគ្គិសនីស្ទឹងមេទឹក (មណាម) ត្រូវបានអនុញ្ញាតអោយមានក្រុមការងារជាអ្នកឯកទេស សំរាប់ជួយរាល់កិច្ចការពាក់ព័ន្ធ និង គំរោងស្ថាបនារ៉ាវីអគ្គិសនីនេះដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឃី តាំងលីម** អនុប្រធានគណៈកម្មការជាតិទន្លេមេគង្គ ប្រធាន

២-ឯកឧត្តម **លឹម គានហោ** អគ្គនាយកធារាសាស្ត្រ អនុប្រធាន

៣-លោក **អ៊ុង ថ័ន** អភិបាលរងខេត្តកោះកុង សមាជិក

៤-លោក **ធីក គ្រឿនវុត្ថា** ទីប្រឹក្សាក្រសួងមហាផ្ទៃ សមាជិក

៥-វរៈសេនីយ៍ឯក **ម៉ែត នរិន្ទ** នាយករង នាយកដ្ឋានវិស្វកម្មនៃក្រសួងការពារជាតិ សមាជិក

៦-លោក **សយ សុខា** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧-លោក **សុខ សារ៉ិន** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨-លោក **ប៊ុន ណារិទ្ធិ** តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល សមាជិក

៩-លោក **អ៊ុង គិរុន** តំណាងក្រសួងបរិស្ថាន សមាជិក

១០-លោក **ប៊ិច សុខែម** តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សមាជិក

ក្រុមការងារនេះមានសិទ្ធិបន្ថែមនូវសមាសភាពមន្ត្រីជំនាញជាជំនួយការតាមសេចក្តីត្រូវការចាំបាច់។

**មាត្រា ៤** : គណៈកម្មការរ៉ាវីអគ្គិសនីស្ទឹងមេទឹក (មណាម) មានភារកិច្ច :

១-ជំរុញការងារសិក្សាស្រាវជ្រាវកសាងឯកសារបច្ចេកទេស និង សេដ្ឋកិច្ច ស្តីពីគំរោងសាងសង់រ៉ាវី អគ្គិសនីស្ទឹងមេទឹក (មណាម) ។

២–ធ្វើការចរចាជាមួយភាគីថៃពីលទ្ធភាពនៃការប្រើប្រាស់ និង អភិវឌ្ឍន៍ធនធានរ៉ែក នៃស្ទឹងមេទឹក ( មណាម ) ដើម្បីជាផលប្រយោជន៍នៃប្រទេសទាំងពីរ ។

៣–ទំនាក់ទំនងស្វែងរកជំនួយពីអង្គការអន្តរជាតិ និងពីបណ្តាប្រទេសនានា ។

៤–ពិនិត្យសិក្សាជ្រើសរើសក្រុមហ៊ុនឯកជនដែលមានលទ្ធភាពធ្វើការសិក្សាស្រាវជ្រាវ បច្ចេកទេសជាបឋម (Prefeasibility study) និងសិក្សាស្រាវជ្រាវអំពី លទ្ធភាពកសាងគំរោង (feasibility study) ។

៥–ពិនិត្យជ្រើសរើសក្រុមហ៊ុនដែលអាចមានលទ្ធភាពធ្វើវិនិយោគក្នុងការងារនេះ ។ រួចធ្វើរបាយការណ៍ពីលទ្ធផលរបស់ខ្លួន ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**មាត្រា ៥ :** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង និង ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធនិងសាមីជនមានភារកិច្ចទទួល អនុវត្តនូវអនុក្រឹត្យនេះចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី ១** — **ព្រះហស្តលេខា និងត្រា** — **នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២** — **ហត្ថលេខា និងត្រា** — **ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

## អនុក្រឹត្យ លេខ : ១២ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មការដឹកនាំសំរបសំរួល និង អង្គភាពអនុវត្តគំរោងការស្តារ និងកែលំអអាកាសយានដ្ឋានខេត្តសៀមរាប

* * *

### រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា